**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

“...ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព”

**ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍**

លេខ : ១៤៤០ បទ.រប

**សូមជម្រាបជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកទូរទស្សន៍ជាតិកម្ពុជា**

**កម្មវត្ថុ** : សំណើសូមជួយធ្វើការផ្សព្វផ្សាយបទបញ្ជា ស្តីពីវិធានការបញ្ឈប់ការបិទខ្ទប់ការតភ្ជាប់បណ្តាញសេវាទូរស័ព្ទគ្នាទៅវិញទៅមករវាងប្រតិបត្តិករទូរស័ព្ទមួយ ទៅប្រតិបត្តិករទូរស័ព្ទមួយទៀត ។

**យោង** : លិខិតរាជរដ្ឋាភិបាលកម្ពុជាលេខ ០១ បប ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៩.

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជំរាបឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកទូរទស្សន៍ជាតិកម្ពុជា ជ្រាបថា : ដើម្បីឱ្យបទបញ្ជា ស្តីពីវិធានការបញ្ឈប់ការបិទខ្ទប់ការតភ្ជាប់បណ្តាញ សេវាទូរស័ព្ទគ្នាទៅវិញទៅមករវាងប្រតិបត្តិករទូរស័ព្ទមួយ ទៅប្រតិបត្តិករទូរស័ព្ទមួយទៀត បានជ្រួតជ្រាបទូទាំងប្រទេស ខ្ញុំស្នើសុំឯកឧត្តមមេត្តាជួយធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធទូរទស្សន៍ជាតិកម្ពុជា ដោយអនុគ្រោះ ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើសូមឯកឧត្តម ជួយផ្សព្វផ្សាយឱ្យបានឆាប់តាមដែលអាចធ្វើទៅបានតាមការគួរ។

សូម **ឯកឧត្តម** ទទួលនូវការរាប់អានអំពីខ្ញុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៩

**តប. រដ្ឋមន្ត្រី**

**អគ្គនាយករដ្ឋបាល**

**ព្រុំ សុន្ធរ**